ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា
លេខ ២៣.០២៤.ធ.ជ.ក

ប្រកាស
ស្តីពី
លក្ខណៈសម្គាល់នៃធនប័ត្រអនុស្សាវរីយ៍ ប្រភេទ ២០០០០០ រៀល

អនុលោមទៅតាមអនុក្រឹត្យលេខ ២៣១ អនក្រ.បក របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២៤ ស្តីពីការចេញផ្សាយធនប័ត្រអនុស្សាវរីយ៍ ប្រភេទ ២០០០០០ រៀល ក្នុងព្រះរាជាណាចក្រកម្ពុជា ធនាគារជាតិនៃកម្ពុជា សូមប្រកាសផ្សាយជាសាធារណៈនូវលក្ខណៈសម្គាល់នៃធនប័ត្រអនុស្សាវរីយ៍នេះ មានដូចខាងក្រោម ៖

ក- លក្ខណៈទូទៅ ៖

- ទំហំធនប័ត្រ : បណ្តោយ ១៧០ មម ទទឹង ៧៦ មម
- ពណ៌ចម្បងគឺពណ៌ត្នោត ពណ៌ទឹកក្រូច និងពណ៌ផ្កាឈូក

ខ- ផ្នែកខាងមុខ ៖

- **ផ្នែកណ្តាល** ត្រូវបានរំលេចឡើងនូវព្រះឆាយាលក្ខណ៍ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តមសីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា រួមជាមួយព្រះវររាជមាតាដែលផ្នែកខាងក្រោយត្រូវបានតែងលំអដោយក្បាច់ចម្លាក់ជាប្រពៃណី ព្រមជាមួយអក្សរ " ពីរសែនរៀល " នៅខាងក្រោម។ ខាងឆ្វេងមានលេខ " ២០០០០០ " នៅពីលើ ព្រមទាំងហត្ថលេខារបស់អគ្គទេសាភិបាលកិត្តិយស អគ្គទេសាភិបាល និងអគ្គបេឡា ខិតមកក្រោមមានរូបចម្លាក់នាគមួយគូ នៅប្រាសាទបន្ទាយសំរ៉ែក្នុងខេត្តសៀមរាប។
- **ផ្នែកខាងស្តាំ** ខាងលើមានអក្សរ " ធនាគារជាតិនៃកម្ពុជា " ខិតមកក្រោមមានលេខមាលាបោះពុម្ពដោយទឹកខ្មៅពណ៌ក្រហម និងនៅពីក្រោមនោះមានលេខ « ២០០០០០ » និង " 200000 " និងមានអក្សរ " អ្នកក្លែងក្រដាសប្រាក់នឹងត្រូវផ្តន្ទាទោសតាមច្បាប់ " នៅគែមខាងក្រោម ។ នៅគែមខាងស្តាំនៃក្រដាសប្រាក់ មានរូបភាពអង្គដៅចំណាំបោះពុម្ពតាមបន្ទាត់បញ្ឈរដែលឆ្លុះឃើញមានលេខ " 200000 " ។
- **ផ្នែកខាងឆ្វេង** ខាងលើមានរូបព្រះសង្ហារនៃព្រះរាជាណាចក្រកម្ពុជា និងមានលេខ

" 200000 " ព្រាលៗបោះពុម្ពតាមបន្ទាត់បណ្ណរ ព្រមជាមួយបន្ទះហ្ងឡូក្រោមទំហំ ១០ មម កាត់ទទឹងផ្ទៃក្រដាសប្រាក់ពីលើដល់ក្រោម។ នៅជ្រុងខាងក្រោមមានគំនូសបន្ទាត់សម្រាប់ផ្ទៀងផ្ទាត់ និងនិមិត្តសញ្ញាពិសេសសម្គាល់ប្រភេទប្រាក់សម្រាប់ជនពិការភ្នែក។

គ- ផ្នែកខាងខ្លួន ៖

- **ផ្នែកកណ្តាល** ត្រូវបានរំលេចឡើងនូវ **ព្រះនាយាល័ក្ខណ៍ព្រះករុណា ព្រះបាទ សម្តេចព្រះបរមនាថ នរោត្តមសីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់គ្រឿងព្រះមហាក្សត្រ និងមានអក្សរ " ពីរសែនរៀល " នៅពីក្រោម និងអក្សរ " Congratulations on the 20th Anniversary of the Coronation of His Majesty Preah Bat Samdech Preah Boromneath NORODOM SIHAMONI (29 October 2004-29 October 2024) " នៅគែមក្រដាសប្រាក់។

- **ផ្នែកខាងស្តាំ** ត្រូវបានរំលេចឡើងនូវរូបភាពប្រាសាទបាយ័នក្នុងខេត្តសៀមរាប និងមានលេខ « ២០០០០០ » នៅផ្នែកខាងក្រោម ព្រមជាមួយខ្សែសុវត្ថិភាព ទំហំ ៣ មម នៅផ្នែកខាងឆ្វេង។ នៅជ្រុងលើខាងស្តាំមានលេខ " 200000 " ដែលត្រូវបានបោះពុម្ពតាមបន្ទាត់បណ្ណរ។

- **ផ្នែកខាងឆ្វេង** ខាងលើមានអក្សរ " ធនាគារជាតិនៃកម្ពុជា " និងអក្សរ " NATIONAL BANK OF CAMBODIA " ខិតមកក្រោមមានចារឹកអក្សរ " អបអរសាទរខួប ២០ឆ្នាំ នៃការគ្រងរាជសម្បត្តិ **ព្រះករុណា ព្រះបាទ សម្តេចព្រះបរមនាថ នរោត្តមសីហមុនី** (២៩ តុលា ២០០៤ - ២៩ តុលា ២០២៤) " ព្រមទាំងលេខ " 2024 " នៅពីក្រោមនោះ។ នៅគែមខាងឆ្វេងនៃក្រដាសប្រាក់មានរូបភាពអង្គដៅចំណាំ បោះពុម្ពតាមបន្ទាត់បណ្ណរ ដែលឆ្លុះឃើញលេខ " 200000 "។

ចាប់ពីថ្ងៃចេញប្រកាសនេះតទៅ ធនប័ត្រអនុស្សាវរីយ៍ប្រភេទ ២០០០០០ រៀល ត្រូវបានដាក់ឲ្យចរាចរទន្ទឹមគ្នាជាមួយនឹងធនប័ត្រជាតិប្រភេទផ្សេងៗទៀត ដែលត្រូវបានចេញផ្សាយកន្លងមក។ សាធារណជនគ្រប់រូប ត្រូវពិនិត្យ សម្គាល់ធនប័ត្រថ្មីនេះឱ្យបានច្បាស់លាស់ ដើម្បីជៀសវាងការភ័ន្តច្រឡំ ។

ថ្ងៃពុធ ១៤ កើត ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០២៤

ទេសាភិបាល

ជា សីរី